**ជំនួយបច្ចេកទេសក្នុងការកសាងសមត្ថភាពថ្នាក់តំបន់**
**ការពង្រឹងសមត្ថភាពផ្នែកនីតិបរិស្ថាននៅអាស៊ី ប៉ាស៊ីហ្វិក៖**
**ការអភិវឌ្ឍជើងឯកផ្នែកបរិស្ថាន**
**ការបណ្តុះបណ្តាលគ្រូបង្គោល**
**ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៧**
**ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា**

# វិធីសាស្រ្តផ្សេងទៀតក្នុងដំណោះស្រាយវិវាទបរិស្ថាន

## លំហាត់សម្តែងតួ៖ ការសម្រុះសម្រួល

វគ្គទី 7 នៅថ្ងៃ អង្គារ ទី 28 ខែ វិច្ឆិកា និងវគ្គទី 12 នៅថ្ងៃ ពុធ ទី 29 ខែ វិច្ឆិកា

### ការណែនាំ

លំហាត់សម្តែងតួនេះត្រូវបានរៀបចំឡើងដើម្បីលើកទឹកចិត្តសិស្សឱ្យពិនិត្យមើលទិដ្ឋភាពផ្សេងៗគ្នានៃស្ថានភាពជាក់ស្តែងដូចគ្នា ដោយប្រើប្រាស់ច្បាប់ក្រោមយុត្តាធិការរបស់ខ្លួន និងដើម្បីចូលរួមក្នុងដំណើរការសម្រុះសម្រួលដោយធ្វើលំហាត់ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ស្ថានភាពជាក់ស្តែងដែលបានជ្រើសរើសនេះ គឺជាសេណារីយ៉ូសម្មតិកម្ម។

លំហាត់សម្តែងតួនេះនឹងធ្វើឡើងជាពីរផ្នែក។ ផ្នែកទីមួយ គឺជាការណែនាំមួយដែលទាក់ទងទៅនឹងសេណារីយ៉ូដែលត្រូវសម្តែងតួរួមជាមួយការណែនាំអំពីរបៀបធ្វើលំហាត់ ។ ផ្នែកនេះនឹងត្រូវបានធ្វើឡើងក្នុងអំឡុងវគ្គទី 7 នៅថ្ងៃទី 2 ថ្ងៃ អង្គារ ទី 28 ខែ វិច្ឆិកា ចាប់ពីម៉ោង 2:25 ដល់ 3:15 រសៀល។ នៅក្នុងវគ្គនេះអ្នកចូលរួមនឹងត្រូវបែងចែកជាក្រុម និងផ្តល់ពេលវេលាដើម្បីអាន និងពិភាក្សាអំពីស្ថានភាពជាក់ស្តែង និងដើម្បីរៀបចំគោលជំហរ និងជម្រើសក្នុងការចរចារបស់ខ្លួន។

ផ្នែកទី 2 នៃការធ្វើលំហាត់នេះ គឺការសម្រុះសម្រួលក្នុងការសម្តែងតួដោយខ្លួនឯង។ ផ្នែកនេះនឹងត្រូវបានធ្វើឡើងក្នុងវគ្គទី 12 នៅថ្ងៃទី 3 ថ្ងៃ ពុធ ទី 29 ខែ វិច្ឆិការ ចាប់ពីម៉ោង 3:30 និង 4:30 ល្ងាច។

បន្ទាប់ពីការសម្តែងតួ មានឱកាសសម្រាប់ធ្វើការឆ្លុះបញ្ចាំង និងផ្តល់មតិយោបល់ ស្តីពីការសម្តែងតួ និងការពិភាក្សាអំពីថាតើអ្នកចូលរួមអាចបញ្ចូលសកម្មភាពសម្តែងតួនេះចូលទៅក្នុងវគ្គសិក្សាអំពីនីតិបរិស្ថានបាន ឬទេ និងបានដោយរបៀបណា។

## ការណែនាំ

1. អ្នកសម្រុះសម្រួលពីរនាក់នឹងត្រូវតែងតាំងឱ្យដឹកនាំការសម្រុះសម្រួល។
2. អ្នកចូលរួមក្រៅពីនេះនឹងត្រូវបានបែងចែកជា 5 ក្រុម ដែលម្នាក់ៗនឹងត្រូវបានបែងចែកតួនាទីជាក់លាក់មួយដែលពួកគេសន្មត់ថានឹងត្រូវបំពេញក្នុងការសម្រុះសម្រួល។
3. ក្រុមនីមួយៗគួរជ្រើសរើសអ្នករាយការណ៍ដែលនឹងកត់ត្រាតំណាងឱ្យក្រុមនេះ ហើយត្រូវរៀបចំសង្ខេបការពិភាក្សាដោយសរសេរលើក្ដារខៀន ឬ កុំព្យូទ័រ។
4. ក្រុមនីមួយៗគួរជ្រើសរើសអ្នកចូលរួមពីរនាក់ដើម្បីដឹកនាំការពិភាក្សា និងតំណាងឱ្យពួកគេនៅក្នុងការសម្រុះសម្រួល។
5. សមាជិកម្នាក់ៗផ្សេងទៀតរបស់ក្រុមនេះរំពឹងថានឹងជួយប្រធានក្រុមរបស់ខ្លួននៅក្នុងកិច្ចពិភាក្សា និងការចរចា។
6. គ្រូឧទ្ទេសនឹងនៅទីនោះសម្រាប់ជួយផ្ដល់ការស្រាយបំភ្លឺ និងគំនិតក្នុងកំឡុងរៀបចំតាមក្រុមនីមួយៗ។

## អង្គហេតុក្នុងសម្មតិកម្ម

ក្នុងឆ្នាំ 2010 ដីមួយចំនួន (ដីឯកជនរបស់រដ្ឋ) ត្រូវបានកំណត់ដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងគោលបំណងដើម្បីសាងសង់លំនៅដ្ឋានសាធារណៈសម្រាប់អ្នកមានប្រាក់ចំណូលទាបនិងអ្នកមានប្រាក់ចំណូលមធ្យម។ នាយកដ្ឋានលំនៅដ្ឋាន ដែលជាផ្នែកមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញលិខិតអនុញ្ញាតសាងសង់ដល់ក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យដើម្បីសាងសង់លំនៅដ្ឋានសាធារណៈនៅលើដីដែលកំណត់នោះ។ វិធានការទាំងនេះត្រូវបានដាក់ចេញដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មុនពេលវាយតម្លៃដីនេះដោយក្រសួងបរិស្ថាន ដើម្បីកំណត់ថាវាសមស្របសម្រាប់លំនៅដ្ឋាន។

ក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យបានចាប់ផ្ដើមសាងសង់អគារលំនៅដ្ឋានក្នុងឆ្នាំ 2011 ហើយនៅឆ្នាំ 2010 បានលក់ដីទាំងអស់សម្រាប់ធ្វើលំនៅដ្ឋានដែលខ្លួនបានសាងសង់។

ប្រាំមួយឆ្នាំបន្ទាប់ពីការរើទៅផ្ទះថ្មីរបស់ខ្លួន ម្ចាស់ផ្ទះមានការភ្ញាក់ផ្អើលជាខ្លាំងដែលឮថាជីវិតរបស់ពួកគេស្ថិតក្នុងគ្រោះថ្នាក់ព្រោះផ្ទះនេះត្រូវបានសាងសង់នៅលើដីដែលត្រូវបានបំពុលដោយការបំពុលពីឧស្សាហកម្មកាត់ដេរ។ ដីនេះត្រូវបានបំពុលដោយម្ចាស់មុនដែលបានដំណើរការរោងចក្រកាត់ដេរមួយដែលបានបញ្ចេញសារធាតុពុលខ្ពស់ក្នុងពណ៌ក្រណាត់។ ពួកគេបានលក់ដីនេះទៅឱ្យរដ្ឋាភិបាលនៅក្នុងឆ្នាំ 2009 ។

ការវាយតម្លៃបរិស្ថានថ្មីៗដោយក្រសួងបរិស្ថានបានបង្ហាញថា តំបន់នេះត្រូវបានបំពុលដោយសារជាតិពុលគីមីផ្សេងៗចេញពីពណ៌ក្រណាត់ដែលអាចបណ្ដាលអោយមានការរលាកភ្នែក ច្រមុះ បំពង់ក និងស្បែក និងបង្កឱ្យ

មានការគាំងបេះដូង។ ថ្មីៗនេះ ដោយសារតែការលេចធ្លាយនៅក្នុងធុងទឹកក្រោមអគារ ទឹកភ្លៀងត្រូវបានបំពុលដោយលោហធាតុធ្ងន់ដែលត្រូវបានរកឃើញនៅក្នុងទឹកផឹករបស់អ្នករស់នៅក្នុងលំនៅដ្ឋាននោះ។

ម្ចាស់លំនៅដ្ឋានបច្ចុប្បន្នកំពុងទទួលរងផលប៉ះពាល់សុខភាពដែលពួកគេចាត់ទុកថាជាកើតឡើងពីលទ្ធផលនៃការរស់នៅលើកន្លែងដែលទទួលរងការបំពុលពីព្រោះពួកគេធ្លាប់មានសុខភាពល្អមុនពេលពួកគេផ្លាស់ប្តូរមករស់នៅក្នុងគម្រោងអភិវឌ្ឍន៍នេះ។ មនុស្សជាច្រើនបានទទួលរងនូវការរលាកភ្នែក ប្រមុះ បំពង់ក និងស្បែក ពិសេសមនុស្សចាស់ និងកុមារតូចៗ។ ប្រជាពលរដ្ឋ 5 នាក់បានជួបប្រទះជំងឺគាំងបេះដូង។ បុរសបីនាក់បានស្លាប់នាពេលថ្មីៗនេះ។

ប្រជាពលរដ្ឋបានព្យាយាមទាក់ទងមកក្រសួងបរិស្ថាន ដែលមានសមត្ថកិច្ចក្នុងការដោះស្រាយដីដែលបានបំពុលនោះ ដោយយកសារធាតុគីមីពុលនោះចេញពីដី និងទឹកក្រោមដី ប៉ុន្តែគេប្រាប់ប្រជាពលរដ្ឋថា ក្រសួងបរិស្ថានមិនមានធនធានដើម្បីជួយតាមមធ្យោបាយនេះទេ។ មានការពិបាកជាក់ស្តែងគួរឱ្យកត់សម្គាល់ក្នុងការចូលទៅក្នុងដីក្រោមផ្ទះរបស់ប្រជាពលរដ្ឋខណៈពេលដែលពួកគេកំពុងបន្តរស់នៅក្នុងផ្ទះរបស់ខ្លួន។

ប្រជាពលរដ្ឋ និងម្ចាស់ផ្ទះចង់ជួបជាមួយក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងម្ចាស់ដើមរបស់រោងចក្រកាត់ដេរ។ ភាគីទាំងអស់បានយល់ព្រមចូលរួមក្នុងការសម្រុះសម្រួលដើម្បីព្យាយាមដោះស្រាយវិវាទនេះ។

**ភាគីទាំងប្រាំមានដូចជា៖**

1) ប្រជាពលរដ្ឋ និងម្ចាស់លំនៅដ្ឋាន

2) ក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ

3) ក្រសួងបរិស្ថាន

4) ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

5) ម្ចាស់ដើមរបស់រោងចក្រកាត់ដេរ

**ការបកស្រាយសម្រាប់ភាគីនីមួយៗ**

ការបកស្រាយទឡ្ហីករណ៍ខ្លីៗមួយដែលភាគីនីមួយៗក្នុងចំណោមភាគីទាំងប្រាំចង់បង្ហាញក្នុងការសម្រុះសម្រួលនឹងត្រូវបានផ្តល់ជូនដល់ភាគីនីមួយៗនៅក្នុងវគ្គទី 7 ។ ភាគីនឹងមិនឃើញការបកស្រាយដែលបានផ្តល់ទៅឱ្យភាគីទាំងបួនផ្សេងទៀត។